ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ២២១៤ សហវ.អល

# លិខិតបង្គាប់ការ
# ស្តីពី
# បង្កើតក្រុមលេខាធិការបូកសរុប តាមដាន និងត្រួតពិនិត្យ លើការងារកែទម្រង់ និងការងារក្រៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន

## អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន
## ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- យោងសារាចរលេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងសារាចរលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការនីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ២៦៥ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៦ នៃប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងសារាចរលេខ ០០៣ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៥ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃ០៤ ខែមិថុនា ឆ្នាំ២០១៤ និង បទប្បញ្ញត្តិវិសោធនកម្មពាក់ព័ន្ធ សម្រាប់ឆ្នាំ២០១៥។
- យោងតម្រូវការចាំបាច់របស់អគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត “**ក្រុមលេខាធិការបូកសរុប តាមដាន និងត្រួតពិនិត្យ លើការងារកែទម្រង់ និងការងារក្រៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**” ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | លោក **គុយ សាធុធ** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន | ប្រធាន |
| ២. | លោកស្រី **អួន រដ្ឋា** | ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន | អនុប្រធាន |
| ៣. | លោក **ម៉ុន ចាន់ទេវស្សសក្តិ** | មន្ត្រីលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ៤. | កញ្ញា **ឃុន សរណា** | មន្ត្រីលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| ៥. | លោក **តុប ច័ន្ទពុទ្ធីល័ក្ខ** | មន្ត្រីលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន | សមាជិក |

៦. លោក **ឡុង រស្មី** មន្ត្រីលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន លេខាធិការ

**ប្រការ២.-**

**ក្រុមលេខាធិការបូកសរុប តាមដាន និងត្រួតពិនិត្យ លើការងារកែទម្រង់ និងការងារក្រៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន** មានតួនាទីនិងភារកិច្ចធ្វើជាលេខាធិការជូនប្រធាន "ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន" (ក.ហ.ស) ដូចខាងក្រោម÷

- សម្របសម្រួលលើការរៀបចំនិងបូកសរុបផែនការសកម្មភាពការងារកែទម្រង់ និងការងារក្រៅកែទម្រង់ របស់អង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន
- សម្របសម្រួលរៀបចំការកែសម្រួលផែនការសកម្មភាពការងារកែទម្រង់ និងការងារក្រៅកែទម្រង់ របស់អគ្គលេខាធិការដ្ឋាន
- សម្របសម្រួលបូកសរុប និងផ្តល់យោបល់កែលម្អ លើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលរៀបចំកិច្ចប្រជុំជូន "ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" និងការងារក្រៅកែទម្រង់ របស់អគ្គលេខាធិការដ្ឋាន
- សម្របសម្រួលជូន អ.គ.ហ និងក្រសួង ក្នុងការរៀបចំនិងបូកសរុបរបាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម របស់អគ្គលេខាធិការដ្ឋាន
- បូកសរុបឈ្មោះមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ដែលស្នើសុំប្រាក់ឧបត្ថម្ភស្របតាមប្រកាសលេខ ៦១៦
- បូកសរុបបញ្ជីវត្តមានមន្ត្រីរបស់អគ្គលេខាធិការដ្ឋានប្រចាំខែ
- អនុវត្តការងារផ្សេងទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន។

**ប្រការ៣.-**

ក្រុមលេខាធិការបូកសរុប តាមដាន និងត្រួតពិនិត្យ លើការងារកែទម្រង់ និងការងារក្រៅកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់អគ្គលេខាធិការ ។

**ប្រការ៤.-**

សមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តលិខិតបង្គាប់ការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋាន**

**មាស សុខសេនសាន**

**ចម្លងជូន÷**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី
-ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក
-ឯកឧត្តមអគ្គលេខាធិការ នៃអគ្គលេខាធិកាដ្ឋាន
 គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
-ឯកសារ-កាលប្បវត្តិ